ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

សាលាដំបូង ខេត្តសៀមរាប

-សំណុំរឿងរដ្ឋប្បវេណី លេខ ២៨៦
ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០
-សាលក្រម លេខ ៣៨ "ច"
ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០

# សាលក្រម
## តាងនាមប្រជារាស្ត្រខ្មែរ
## សាលាដំបូងខេត្តសៀមរាប

បានបញ្ចប់ការទាញហេតុផលដោយផ្ទាល់មាត់ ថ្ងៃសុក្រ ១៤រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤ ត្រូវនឹងថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០ ព្រឹក នៅសាលជំនុំជម្រះនៃ សាលាដំបូង ខេត្តសៀមរាប លើសំណុំរឿងរដ្ឋប្បវេណី លេខៈ ២៨៦ ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ ដោយមានសមាសភាព ដូចតទៅៈ

**ចៅក្រមជំនុំជម្រះ**

-លោកស្រី [redacted] ចៅក្រមសាលាដំបូង ខេត្តសៀមរាប

**ក្រឡាបញ្ជីសវនាការ**

-លោកស្រី [redacted] ក្រឡាបញ្ជីសាលាដំបូង ខេត្តសៀមរាប

**ដើមចោទ**ឈ្មោះ [redacted] ភក្តី ភេទស្រី អាយុ៣៦ឆ្នាំ អាសយដ្ឋាន សញ្ជាតិខ្មែរ [redacted]។

**ចុងចម្លើយ**ឈ្មោះ [redacted] វាសនា ភេទប្រុស អាយុ៣៥ឆ្នាំ សញ្ជាតិខ្មែរ អាសយដ្ឋាន [redacted]។

មានលោក [redacted] ជាមេធាវីតំណាងដោយអាណត្តិ។

**អង្គហេតុ និងចំណុចវិវាទ**

I-ការទាមទាររបស់ដើមចោទៈ

ដើមចោទបានប្តឹងសុំទាមទារឲ្យតុលាការចេញសាលក្រម ដូចខាងក្រោមៈ

១.សុំផ្តាច់អនីតិសង្វាសពីឈ្មោះ [redacted] វាសនា និងសុំសិទ្ធិមានអំណាចមេបាលើកូន ចំនួន ០២នាក់ ឈ្មោះ [redacted] សុខគង់ ភេទប្រុស កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ និង ឈ្មោះ [redacted] សុខមាន ភេទស្រី កើតថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨។

២.ឲ្យចុងចម្លើយ បង់អាហារកាតព្វកិច្ចចិញ្ចឹមបីបាច់កូនតាមលទ្ធភាព រហូតដល់កូនគ្រប់អនីតិភាព។

៣.ដីមួយកន្លែង ទំហំ (២៣៧) ម៉ែត្រការ៉េ មានទីតាំងនៅ ភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដើមចោទសុំសិទ្ធិគ្រប់គ្រងទុកឲ្យកូនរស់នៅ។

៤.ប្រាក់ប្រដាប់ក្តី ភាគីដើមចោទរ៉ាប់រងបង់តែម្នាក់ឯង។

II-ដំណើររឿងក្តី និងចំណុចវិវាទ

១-ការសង្ខេបអំពីរឿងក្តី

ដើមចោទឈ្មោះ [redacted] ភក្តី ភេទស្រី និងចុងចម្លើយឈ្មោះ [redacted] វ៉ាសនា ភេទប្រុស បានរួមរស់នៅជាមួយគ្នាជាប្តីប្រពន្ធ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ ត្រឹមត្រូវតាមច្បាប់ទេ។ ក្នុងពេលរួមរស់នៅជាមួយគ្នាដើមចោទ និងចុងចម្លើយ មានកូនចំនួន០២នាក់ គឺឈ្មោះ [redacted] សុខគង់ ភេទប្រុស កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ និងឈ្មោះ [redacted] សុខហាន ភេទស្រី កើតថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨ និងទ្រព្យសម្បត្តិរួមគ្នា ដូចខាងលើ ផងដែរ។ ដោយសាររស់នៅមិនចុះសម្រុងនឹងគ្នា ដើមចោទបានសម្រេចចិត្តដាក់ពាក្យបណ្តឹងសុំលែងលះ ហើយចុងចម្លើយក៏បានយល់ព្រមគ្រប់ចំណុចនៃការទាមទាររបស់ដើមចោទ។

២-ចំណុចវិវាទៈ គ្មាន។

III.សេចក្តីថ្លែងការណ៍របស់គូភាគី

ឈ្មោះ [redacted] ភក្តី ជាដើមចោទបានធ្វើសេចក្តីថ្លែងការណ៍ថា ខ្លួនអាចឆ្លើយខ្លួនឯងបាន ដោយមិនចាំបាច់មានមេធាវីចូលរួមទេ។ ពីមុនខ្លួន និងឈ្មោះ [redacted] វ៉ាសនា បានរៀបអាពាហ៍ពិពាហ៍ជាមួយគ្នា តាំងពីឆ្នាំ២០០៦ និងបានចុះសំបុត្រអាពាហ៍ពិពាហ៍ជាមួយគ្នាត្រឹមត្រូវ ដូចក្នុងសំបុត្រអាពាហ៍ពិពាហ៍ លេខ ០៣ ចុះថ្ងៃទី២៦ ខែកុម្ភៈ ឆ្នាំ២០០៧ ហើយខ្លួនមានកូនម្នាក់ ក្រោយមកខ្លួន និងឈ្មោះ [redacted] វ៉ាសនា រស់នៅមិនចុះសម្រុងនឹងគ្នា ខ្លួនក៏បានដាក់ពាក្យបណ្តឹងលែងលះ ទៅតុលាការខេត្តបាត់ដំបង ដើម្បីសុំលែងលះឈ្មោះ [redacted] វ៉ាសនា ហើយតុលាការក៏បានចេញសាលក្រមសម្រេចឲ្យលែងលះ និងប្រគល់កូនម្នាក់ឲ្យខ្លួន ប៉ុន្តែបច្ចុប្បន្នកូនម្នាក់នោះបានស្លាប់ហើយ។ បន្ទាប់ពីលែងលះរួច ក្រោយមកខ្លួន និងឈ្មោះ [redacted] វ៉ាសនា បានត្រូវរ៉ូវគ្នា និងរស់នៅជាប្តីប្រពន្ធវិញ ប៉ុន្តែមិនបានចុះសំបុត្រអាពាហ៍ពាហ៍ថ្មីនោះទេ ដោយក្នុងពេលរស់នៅជាប្តីប្រពន្ធថ្មីនេះ ខ្លួនមានកូនពីរនាក់ឈ្មោះ [redacted] សុខគង់ ភេទប្រុស កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ និងឈ្មោះ [redacted] សុខហាន ភេទស្រី កើតថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨ និងមានដីមួយកន្លែង ទំហំ (២៣៧) ម៉ែត្រការ៉េ មានទីតាំងនៅ ភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលឈ្មោះ [redacted] វ៉ាសនា គាត់ដាក់ឈ្មោះគាត់តែម្នាក់ទេ ដោយសារពេលនោះ ខ្លួន និងគាត់មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ថ្មី។ ពេលនេះ ខ្លួន និងឈ្មោះ [redacted] វ៉ាសនា រស់នៅមិនចុះសម្រុងនឹងគ្នា ដូច្នេះ ទើបខ្លួនដាក់ពាក្យបណ្តឹងមកតុលាការ សុំផ្តាច់ទំនាក់ទំនងជាប្តីប្រពន្ធអនីតិសង្វាស់នេះ វិញ និងសុំសិទ្ធិអាណាព្យាបាលលើកូនចំនួន ០២នាក់ ឈ្មោះ [redacted] សុខគង់ ភេទប្រុស កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ និង

ឈ្មោះ [redacted] សុខមាន ភេទស្រី កើតថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨ ដែលជាកូនដែលខ្លួនមានពេលរស់នៅជាប្តីប្រពន្ធជាមួយឈ្មោះ [redacted] វាសនា ដែលមិនបានចុះបុត្រអាពាហ៍ពិពាហ៍ និងសុំឲ្យចុងចម្លើយ បង់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព រហូតដល់កូនគ្រប់នីតិភាព, ចំពោះដីមួយកន្លែង ទំហំ (២៣៧) ម៉ែត្រការ៉េ មានទីតាំងនៅ ភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប គឺខ្លួនសុំសិទ្ធិគ្រប់គ្រងជាបណ្តោះអាសន្នទុកឲ្យកូនទាំងពីររបស់ខ្លួន ចំណែកប្រាក់ប្រដាប់ក្តី ខ្លួនជាអ្នករ៉ាប់រងបង់តែម្នាក់ឯង។ ខ្លួន និងចុងចម្លើយរស់នៅមិនចុះសម្រុងគ្នា មិនអាចរស់នៅជាមួយគ្នាជាប្តីប្រពន្ធបន្តទៀតបាន ដូច្នេះ ស្នើសុំតុលាការចេញសាលក្រម តាមការទាមទាររបស់ខ្លួន។

លោក [redacted] ជាមេធាវីតំណាងអាណត្តិឲ្យចុងចម្លើយបានធ្វើសេចក្តីថ្លែងការណ៍ថា កូនក្តីខ្លួនយល់ព្រមផ្តាច់អនីតិសង្វាសជាមួយដើមចោទឈ្មោះ [redacted] ភក្តី និងយល់ព្រមប្រគល់សិទ្ធិមានអំណាចមេបាលើកូនចំនួន ០២នាក់ ឈ្មោះ [redacted] សុខគង់ ភេទប្រុស កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ និងឈ្មោះ [redacted] សុខមាន ភេទស្រី កើតថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨ ឲ្យទៅដើមចោទ, ព្រមបង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនតាមលទ្ធភាព រហូតដល់កូនគ្រប់នីតិភាព, ចំពោះដីមួយកន្លែង ទំហំ (២៣៧) ម៉ែត្រការ៉េ មានទីតាំងនៅ ភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលជាទ្រព្យសម្បត្តិរួមរវាងកូនក្តីខ្លួន និងដើមចោទ កូនក្តីខ្លួនយល់ព្រមប្រគល់ឲ្យកូនទាំងពីររបស់កូនក្តីខ្លួន ដោយឲ្យដើមចោទមានសិទ្ធិគ្រប់គ្រងជាបណ្តោះអាសន្នរហូតដល់កូនដល់នីតិភាព ចំណែកប្រាក់ប្រដាប់ក្តី ឲ្យភាគីដើមចោទរ៉ាប់រងបង់តែម្នាក់ឯង។

## **សំអាងហេតុ**

តាមលទ្ធផលនៃការពិនិត្យភស្តុតាងនានា នៅក្នុងនីតិវិធីទាញហេតុផលដោយផ្ទាល់មាត់

**ឃើញថា៖**

**១**-តាមពាក្យបណ្តឹង ចុះថ្ងៃទី០៨ ខែកក្កដា ឆ្នាំ២០២០ របស់ឈ្មោះ [redacted] ភក្តី ជាដើមចោទ គឺមានលក្ខណៈត្រឹមត្រូវតាមច្បាប់ ស្របតាមមាត្រា ៧៥ នៃក្រមនីតិវិធីរដ្ឋប្បវេណី គប្បី តុលាការយកមកពិនិត្យ និងសម្រេចតាមច្បាប់បាន។

**២**-ដើមចោទ និងចុងចម្លើយ មិនបានចុះសំបុត្រអាពាហ៍ពិពាហ៍ត្រឹមត្រូវតាមច្បាប់ នៅចំពោះមុខមន្ត្រីអត្រានុកូលដ្ឋានដែលជាមន្ត្រីមានសមត្ថកិច្ចនោះទេ ដូច្នេះ ការរួមរស់នៅជាប្តីប្រពន្ធរវាងដើមចោទ និងចុងចម្លើយមិនមានអានុភាព ជាសហព័ទ្ធ តាមផ្លូវច្បាប់ ជាការរស់នៅបែបអនីតិសង្វាស់ ប្រាកដមែន។

**៣**-តាមសៀវភៅស្នាក់នៅ ចុះថ្ងៃទី២០ ខែកុម្ភៈ ឆ្នាំ២០១៤ របស់អធិការនគរបាល ក្រុងសៀមរាប, សំបុត្របញ្ជាក់កំណើត លេខ ០៥ ចុះថ្ងៃទី២០ ខែមករា ឆ្នាំ២០១៤ របស់មន្ត្រីអត្រានុកូលដ្ឋានសង្កាត់ព្រៃកព្រះស្តេច, សំបុត្រកំណើត លេខ ៣០៤ ចុះថ្ងៃទី៣១ ខែតុលា ឆ្នាំ២០១៨ របស់មន្ត្រីអត្រានុកូលដ្ឋាន សង្កាត់សាលាកំរើក បញ្ជាក់បានថា ដើមចោទ និងចុងចម្លើយ ពិតជាឪពុកម្តាយរបស់

កូនឈ្មោះ មាស សុខគង់ ភេទប្រុស កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ និងឈ្មោះ មាស សុខមាន ភេទស្រី កើតថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨ ប្រាកដមែន ដូច្នេះ គប្បី តុលាការសម្រេចប្រគល់សិទ្ធិមានអំណាចមេបាលើកូនទាំងពីរ ខាងលើ ឲ្យទៅដើមចោទ តាមការព្រមព្រៀង។

**៤**- តាមវិញ្ញាបនបត្រសម្គាល់ម្ចាស់អចលនវត្ថុ លេខ ១៧១០០៤០២-១៦៥៤ ឃើញថា ដីមួយកន្លែង ទំហំ (២៣៧) ម៉ែត្រការ៉េ មានទីតាំងនៅ ភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ដែលមានឈ្មោះចុងចម្លើយឈ្មោះ [redacted] វាសនា ជាម្ចាស់កម្មសិទ្ធិ គឺចុងចម្លើយទទួលស្គាល់ថា ជាទ្រព្យសម្បត្តិរួម ហើយព្រមប្រគល់ដីមួយកន្លែង ខាងលើនេះ ឲ្យទៅកូនទាំងពីររបស់ខ្លួន ដោយឲ្យដើមចោទជាអ្នកមានសិទ្ធិគ្រប់គ្រងជាបណ្ដោះអាសន្ន រហូតដល់កូនដល់នីតិភាព ដូច្នេះ គប្បី តុលាការសម្រេចតាមឆន្ទៈព្រមព្រៀងរបស់គូភាគី។

**៥**- ចំពោះប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូន ដើមចោទ ជាអ្នកមានសិទ្ធិអំណាចមេបា ស្នើសុំឲ្យចុងចម្លើយបង់តាមលទ្ធភាព រហូតកូនដល់នីតិភាព ដូច្នេះ គប្បី តុលាការសម្រេច តាមឆន្ទៈព្រមព្រៀងរបស់គូភាគី។

**៦**- ប្រាក់ប្រដាប់ក្ដី គប្បី តុលាការសម្រេចជាបន្ទុករបស់ដើមចោទ តាមការស្នើសុំ។

## សម្រេចសេចក្ដីបញ្ចប់

I-ទទួលស្គាល់ការទាមទាររបស់ដើមចោទ ដោយឲ្យដើមចោទឈ្មោះ [redacted] កក្កី ដាច់អនីតិសង្វាសពីចុងចម្លើយឈ្មោះ [redacted] វាសនា ចាប់ពីពេលសាលក្រមនេះ ចូលស្ថាពរ។

II-ឲ្យដើមចោទឈ្មោះ [redacted] កក្កី ជាអ្នកមានសិទ្ធិអំណាចមេបាលើកូនចំនួន ០២នាក់ ឈ្មោះ [redacted] សុខគង់ ភេទប្រុស កើតថ្ងៃទី០៥ ខែមិថុនា ឆ្នាំ២០១៣ និងឈ្មោះ [redacted] សុខមាន ភេទស្រី កើតថ្ងៃទី២៧ ខែតុលា ឆ្នាំ២០១៨។

-ភាគីដែលពុំមានអំណាចមេបា មានសិទ្ធិចូលជួបប្រាស្រ័យទាក់ទងនឹងកូនបាន ដើម្បីពិនិត្យមើលស្ថានភាពកូន ដោយភាគីដែលមានអំណាចមេបាមិនត្រូវរារាំងកូនមិនឲ្យមានការប្រាស្រ័យទាក់ទងជាមួយភាគីម្ខាងទៀត ហើយត្រូវបង្កលក្ខណៈងាយស្រួលដល់ភាគីម្ខាងទៀត ពេលទៅសួរសុខទុក្ខកូន យោងតាមមាត្រា ១០៤០ និងមាត្រា ១០៤១ នៃក្រមរដ្ឋប្បវេណី។

III-បង្គាប់ឲ្យចុងចម្លើយឈ្មោះ [redacted] វាសនា បង់ប្រាក់អាហារកាតព្វកិច្ចចិញ្ចឹមកូនទាំងពីរខាងលើ តាមលទ្ធភាព រហូតដល់កូនគ្រប់នីតិភាព។

IV-ទ្រព្យសម្បត្តិរួម ដីមួយកន្លែង ទំហំ (២៣៧) ម៉ែត្រការ៉េ មានទីតាំងនៅ ភូមិវត្តស្វាយ សង្កាត់សាលាកំរើក ក្រុងសៀមរាប ខេត្តសៀមរាប ប្រគល់ឲ្យ ដើមចោទជាអ្នកមានសិទ្ធិគ្រប់គ្រងជាបណ្ដោះអាសន្ន ទុកឲ្យកូនទាំងពីរខាងលើ រហូតកូនដល់នីតិភាព តាមការព្រមព្រៀង។



Scanned with CamScanner

V-ប្រាក់ប្រដាប់ក្តីជាបន្ទុករបស់ដើមចោទ។

-ទុកសិទ្ធិប្តឹងឧទ្ធរណ៍តាមកំណត់ច្បាប់ ក្នុងរយៈពេល ០១ (មួយ) ខែ គិតចាប់ពីថ្ងៃបានទទួលការបញ្ជូនលិខិតសាលក្រមនេះ។

**ចៅក្រមជំនុំជម្រះ**

**ហត្ថលេខា និងត្រា** [redacted]

---

បានឃើញ

ថ្ងៃសុក្រ ១៤រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅសៀមរាប ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០

**ចៅក្រម**

[redacted]

បានថតចម្លងត្រឹមត្រូវតាមច្បាប់ដើម

ថ្ងៃសុក្រ ១៤រោច ខែអស្សុជ ឆ្នាំជូត ទោស័ក ព.ស ២៥៦៤

ធ្វើនៅសៀមរាប ថ្ងៃទី១៦ ខែតុលា ឆ្នាំ២០២០

**ក្រឡាបញ្ជី**

[redacted]



Scanned with CamScanner